

**ផលិតផល ForLife សម្បត្តិខ្ញុំ** គឺជាផលិតផលថ្មីស្រឡាង ដែលផ្តល់ជូនអត្ថប្រយោជន៍ដ៏ច្រើនសម្បើម មិនធ្លាប់មានពីមុនមក កាន់តែពិសេសគឺសម្រាប់លោកអ្នកដែលត្រូវការការសន្សំ និង ការការពារក្នុងកញ្ចប់តែមួយ ជាមួយនឹងភាពងាយស្រួលដោយមិនតម្រូវឱ្យមានការពិនិត្យសុខភាព។ សន្សំតែ២ដងប៉ុណ្ណោះ ប៉ុន្តែទទួលបានការការពាររហូតដល់៥ឆ្នាំពេញ ជាមួយអត្ថប្រយោជន៍ដល់កាលកំណត់ខ្ពស់ស្មើនឹង ១២៥% នៃបុព្វលាភធានារ៉ាប់រងសរុបដែលបានបង់។

## លក្ខខណ្ឌសំខាន់ៗ

- អាយុចាប់ផ្តើមធានារបស់អ្នកត្រូវបានធានារ៉ាប់រង៖ ៣០ ថ្ងៃ ដល់ ៦៥ ឆ្នាំ។
- រយៈពេលនៃបណ្ណសន្យារ៉ាប់រង៖ ៥ ឆ្នាំ។
- ចំនួនបង់បុព្វលាភធានារ៉ាប់រង៖ ២ ឆ្នាំ តែប៉ុណ្ណោះ។
- របៀបបង់បុព្វលាភធានារ៉ាប់រង៖ ប្រចាំឆ្នាំ។
- វិធីបង់បុព្វលាភ៖ ផ្ទេរតាមធនាគារ បញ្ញបង់ប្រាក់អចិន្ត្រៃយ៍ សេវាទូទាត់ ឬផ្ទេរមានអាជ្ញាបណ្ណត្រឹមត្រូវ
- វិសាលភាពនៃការធានារ៉ាប់រង៖ ជាសកលគ្រប់ទីកន្លែង

## សារៈសំខាន់

- ផ្តល់ជូនអត្ថប្រយោជន៍ដល់កាលកំណត់ដែលមានការធានាខ្ពស់ស្មើនឹង១២៥% នៃបុព្វលាភធានារ៉ាប់រងសរុបដែលបានបង់ ប្រសិនបើមិនមានរឿងអកុសលដែលត្រូវបានធានាអ្វីមួយកើតឡើងរហូតដល់ចុងឆ្នាំទី៥នៃផលិតផលនេះ។
- ផ្តល់ជូនអត្ថប្រយោជន៍ការពារចាប់ពី ១០៥% រហូតទៅដល់ ១៣១% នៃបុព្វលាភធានារ៉ាប់រងសរុបដែលបានបង់ លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយមូលហេតុទូទៅ ឬ គ្រោះថ្នាក់។

ខិត្តប័ណ្ណនេះផ្តល់នូវព័ត៌មានបឋមអំពីផលិតផលប៉ុណ្ណោះ។ លោកអ្នកត្រូវអាន ខ និង លក្ខខណ្ឌនៃផលិតផលនេះដើម្បីជ្រាបពីព័ត៌មានលម្អិតហើយស្វែងរកការប្រឹក្សាយោបល់ពីបុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលរបស់យើងខ្ញុំ មុននឹងសម្រេចចិត្តទិញបណ្ណសន្យារ៉ាប់រងនេះ។

Fortune Life Insurance PLC fortunelifecambodia
www.fortunelife.com.kh +855 23 931 999 | 1800-202 202 ឥតគិតថ្លៃ
អគារ The Gateway ជាន់ទី26 មហាវិថីសហព័ន្ធរុស្ស៊ី (ផ្លូវ110) សង្កាត់ផ្សារដេប៉ូទី3 ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Fortune
LIFE INSURANCE

# ផលិតផល ForLife សម្បត្តិខ្ញុំ

ForLife Sambath Knhom

# អត្ថប្រយោជន៍ធានារ៉ាប់រង

## ១ អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍៖

ផ្តល់ជូនទឹកប្រាក់សំណង (ដូចបង្ហាញក្នុងតារាងផែនការជីវិតខ្ញុំ) ផ្អែកទៅតាមឆ្នាំបណ្ណសន្យារ៉ាប់រងដែលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍កើតឡើងចំពោះអ្នកត្រូវបានធានាដូចខាងក្រោម៖

| ឆ្នាំបណ្ណសន្យារ៉ាប់រង | អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (ទឹកប្រាក់ជា % នៃបុព្វលាភធានារ៉ាប់រងដែលបានបង់) |
|---|---|
| 1 | 105% |
| 2 | 110% |
| 3 | 117% |
| 4 | 126% |
| 5 | 131% |

## ២ អត្ថប្រយោជន៍ដល់កាលកំណត់៖

ផ្តល់ជូនអត្ថប្រយោជន៍ដល់កាលកំណត់ **១២៥%** នៃបុព្វលាភធានារ៉ាប់រងសរុបដែលបានបង់ដូចបង្ហាញក្នុងតារាង ផែនការជីវិតខ្ញុំ ដែលនឹងត្រូវទូទាត់ជូននៅកាលបរិច្ឆេទដល់កំណត់ ប្រសិនបើមិនមានរឿងអកុសលដែលត្រូវបានធានាអ្វីមួយកើតឡើងរហូតដល់ចុងឆ្នាំទី៥នៃផលិតផលនេះ។



# ដំណើរការរបស់ផលិតផល

លោក ដារ៉ា អាយុ ៣៥ ឆ្នាំ ទិញផលិតផល **ForLife សម្បត្តិខ្ញុំ** ជាមួយ ហ្វ័រឈូន ឡាយហ្វ៍ ដើម្បីការពារខ្លួនគាត់ និងក្តីស្រមៃរបស់គ្រួសារគាត់ ដែលមានរយៈពេលធានារ៉ាប់រង ៥ឆ្នាំ និងតម្រូវឱ្យបង់បុព្វលាភធានារ៉ាប់រង២ឆ្នាំ ដោយ បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ ៥,០០០ ដុល្លារ ក្នុង១ឆ្នាំ។ ដូច្នេះ លោក ដារ៉ា ត្រូវបង់បុព្វលាភសរុប ១០,០០០ ដុល្លារ។

- ប្រសិនបើ លោក ដារ៉ា មិនមានរឿងអកុសលដែលត្រូវបានធានាអ្វីមួយកើតឡើងរហូតដល់ចុងឆ្នាំទី៥ ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ នឹងទូទាត់ទឹកប្រាក់ចំនួន ១២,៥០០ ដុល្លារ ជូនដល់គាត់ ឬក្រុមគ្រួសាររបស់គាត់នៅកាលបរិច្ឆេទដល់កាលកំណត់នៃផលិតផលនេះ។
- ប្រសិនបើ លោកដារ៉ា ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារជំងឺ ឬគ្រោះថ្នាក់ ក្នុងឆ្នាំទី១ ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ នឹងទូទាត់ទឹកប្រាក់ចំនួន៥,២៥០ ដុល្លារ ជូនដល់គាត់ ឬក្រុមគ្រួសាររបស់គាត់។
- ប្រសិនបើ លោកដារ៉ា ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារជំងឺ ឬគ្រោះថ្នាក់ ក្នុងឆ្នាំទី៣ ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ នឹងទូទាត់ទឹកប្រាក់ចំនួន ១១,៧០០ ដុល្លារ ជូនដល់គាត់ ឬក្រុមគ្រួសាររបស់គាត់។
- ប្រសិនបើ លោកដារ៉ា ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារជំងឺ ឬគ្រោះថ្នាក់ ក្នុងឆ្នាំទី៥ ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ នឹងទូទាត់ទឹកប្រាក់ចំនួន ១៣,១០០ ដុល្លារ ជូនដល់គាត់ ឬក្រុមគ្រួសាររបស់គាត់។

# ករណីមិនធានា៖

រាល់ការទាមទារសំណងចំពោះមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD) របស់អ្នកត្រូវបានធានារ៉ាប់រងទាំងឡាយណាដែលកើតឡើងដោយផ្ទាល់ ឬប្រយោលដោយមូលហេតុខាងក្រោម នឹងមិនត្រូវបានធានាឡើយ៖

ក. ស្ថានភាពសុខភាពកើតមុនពេលធានារ៉ាប់រង ទាក់ទងទៅនឹងជំងឺដូចបានបញ្ជាក់នៅក្នុង
- ផ្នែកទី១៖ និយមន័យ ត្រង់ចំណុច ១.២០ រៀបរាប់នៅក្នុងបណ្ណសន្យារ៉ាប់រង ForLife សម្បត្តិ ខ្ញុំឬ

ខ. ជំងឺពីកំណើត ឬការខ្សោយពីកំណើត ឬ ពិការភាពពីកំណើត ឬភាពមិនប្រក្រតីពីកំណើត ឬ

គ. ពិការភាពរបស់អ្នកត្រូវបានធានារ៉ាប់រង ដែលកើតឡើងមុនពេលកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រងឬមុនកាលបរិច្ឆេទបន្តសុពលភាពឡើងវិញបន្ទាប់ពីការអស់សុពលភាពជាបណ្តោះអាសន្ននៃបណ្ណសន្យារ៉ាប់រងនេះ (ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេបំផុត) ឬ

ឃ. ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬបង្កគ្រោះថ្នាក់ដោយខ្លួនឯង ក្នុងរយៈពេលពីរឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រងនេះ ឬកាលបរិច្ឆេទបន្តកិច្ចសន្យាធានារ៉ាប់រង (ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេបំផុត) ទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬការឆ្លងមេរោគហ៊ីវ(HIV) ឬជំងឺអេដស៍(AIDS) ឬជំងឺផ្សេងៗទៀតដែលពាក់ព័ន្ធនឹងមេរោគហ៊ីវ (HIV) ឬជំងឺអេដស៍ (AIDS) ឬការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ការសេពគ្រឿងស្រវឹងហួសកម្រិតឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬ

ង. ការចូលរួមក្នុងសកម្មភាពខុសច្បាប់ ឬប្រឆាំងនឹងការចាប់ខ្លួនរបស់អាជ្ញាធរ ឬសកម្មភាពលួចចេញពីពន្ធនាគារ ឬ

ជ. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល នូវរាល់បទល្មើសព្រហ្មទណ្ឌដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានដែលបង្កឱ្យអ្នកត្រូវបានធានារ៉ាប់រង ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬ

ឈ. ការចូលរួមរបស់អ្នកត្រូវបានធានារ៉ាប់រង ក្នុងសកម្មភាពសង្គ្រាម ឬក្នុងអំឡុងពេលមានសង្គ្រាម ឬ នៅក្នុងប្រតិបត្តិការសង្គ្រាម(ទោះមាន ឬ មិនមានការប្រកាសជាមុនក៏ដោយ) ឬ សង្គ្រាមស៊ីវិល ឬ ការស្តារសណ្តាប់ធ្នាប់សាធារណៈ ក្នុងកំឡុងពេលមានការបះបោរ អំពើហិង្សារ បដិវត្តន៍ កុប្បកម្ម ឬជម្លោះប្រដាប់អាវុធផ្សេងៗ ឬ គ្រោះមហន្តរាយជាដើម ឬ

ញ. ការចូលរួមរបស់អ្នកត្រូវបានធានារ៉ាប់រង នៅក្នុងសកម្មភាពហោះហើរ ឬអាកាសចរណ៍នានាលើកលែងតែអ្នកត្រូវបានធានារ៉ាប់រងនោះជាអ្នកដំណើរត្រូវបង់ថ្លៃធ្វើដំណើរនៃអាកាសចរណ៍ស៊ីវិលដែលមានកាលវិភាគធ្វើដំណើរត្រឹមត្រូវនិងមានអាជ្ញាបណ្ណត្រឹមត្រូវ ឬ

ដ. ការចូលរួមរបស់អ្នកត្រូវបានធានារ៉ាប់រងនៅក្នុងសកម្មភាពដែលងាយមានគ្រោះថ្នាក់ដូចជាការមុជក្រោមទឹកដែលចាំបាច់ត្រូវប្រើបំពង់អុកស៊ីសែន ការឡើងភ្នំ ការលោតឆ័ត្រយោងការជិះជាមួយឬបើកបរក្នុងការប្រណាំង ឬកីឡាអាជីពណាមួយ។

# ករណីខកខាន ឬយឺតយ៉ាវនៃការបង់បុព្វលាភធានារ៉ាប់រង៖

- រយៈពេលអនុគ្រោះចំនួន 30 (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដល់កាលកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រង នឹងត្រូវបានផ្តល់ជូនសម្រាប់ការទូទាត់បុព្វលាភធានារ៉ាប់រងដែលមិនទាន់បានបង់ ដែលក្នុងរយៈពេលអនុគ្រោះនេះបណ្ណសន្យារ៉ាប់រងនេះនឹងនៅតែមានសុពលភាពដដែល។
- ប្រសិនបើក្រុមហ៊ុននៅតែមិនទទួលបាននូវបុព្វលាភធានារ៉ាប់រងគិតត្រឹមកាលបរិច្ឆេទចុងក្រោយនៃរយៈពេលអនុគ្រោះ នោះបណ្ណសន្យារ៉ាប់រងនឹងអស់សុពលភាព គិតចាប់ពីកាលបរិច្ឆេទដែលត្រូវបង់បុព្វលាភធានារ៉ាប់រងចុងក្រោយ។ ការទទួលខុសត្រូវរបស់ក្រុមហ៊ុននៅក្រោមបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបញ្ចប់ ហើយក្រុមហ៊ុននឹងមិនត្រូវប្រគល់ជូនវិញនូវរាល់បុព្វលាភធានារ៉ាប់រងដែលបានបង់នោះឡើយ។
- ម្ចាស់បណ្ណសន្យារ៉ាប់រងអាចដាក់ពាក្យស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញមកក្រុមហ៊ុននៅក្នុងរយៈពេលយ៉ាងយូរបំផុត 2 (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដល់កាលកំណត់ ត្រូវបង់បុព្វលាភធានារ៉ាប់រងចុងក្រោយ។